ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទាំងអស់មេត្តាជ្រាបថា **ឧបាសិកា រស់ យ៉ា** ដែលត្រូវជាម្តាយក្មេករបស់ **លោក ញ៉ែម សុខជា** ប្រធានមន្ទីរមុខងារសាធារណៈខេត្តព្រៃវែង បានទទួលមរណភាពកាលពីថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ៣:២០នាទីរសៀល ក្នុងជន្មាយុ ៨០ឆ្នាំ ដោយជរាពាធ ។

**ឯកឧត្តម ហាស់ ប៊ុនថូន** អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នឹងដឹកនាំប្រតិភូចូលរួមកម្មវិធីបុណ្យគម្រប់ខួប**៧ថ្ងៃ** ដែលនឹងប្រារព្ធទៅនៅរសៀល**ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២** នៅគេហដ្ឋាន ស្ថិតនៅភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

**លោក ញ៉ែម សុខជា "GNEM SOKCHEA"** មានគណនី **ACLEDA** លេខ 1400-00249334-53 (ដុល្លារ)

លេខ 1400-00249334-34 (រៀល) ។

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងមុខងារសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

## សាររំលែកមរណទុក្ខ

**ជូនចំពោះ**

**លោក ញ៉ែម សុខជា ប្រធានមន្ទីរមុខងារសាធារណៈខេត្តព្រៃវែង ព្រមទាំងក្រុមគ្រួសារ**
**ចំពោះមរណភាពរបស់ ឧបាសិកា រស់ យ៉ា**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្តុកក្តួល និង សោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឧបាសិកា រស់ យ៉ា** ជាម្តាយក្មេករបស់លោក បានទទួលមរណភាព នៅថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹង ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ៣:២០នាទីរសៀល ក្នុងជន្មាយុ ៨០ឆ្នាំ ដោយជរាពាធ ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ចំពោះ ការបាត់បង់ **ឧបាសិកា រស់ យ៉ា** ជាម្តាយបង្កើត ម្តាយក្មេក និងជាជីដូនប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្តីសោកសង្រេងបំផុតជាមួយ **លោក ព្រមទាំង ក្រុមគ្រួសារ** និងសូមសម្តែងនូវការគោរពចំពោះដួងវិញ្ញាណក្ខ័ន្ធរបស់ **ឧបាសិកា រស់ យ៉ា** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក ញ៉ែម សុខជា ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ សុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**